00717660

E100/4

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
17 / 01 / 2014
ម៉ោង (Time/Heure): 10:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ បារាំង

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សារណាគាំទ្រសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត

---

**<u>ដាក់ដោយ</u>៖**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ពេជ អង្គ

មេធាវី Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ជេត វណ្ណលី

**<u>ដាក់ជូន</u>៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

មេធាវី ហុង គឹមសួន
មេធាវី គីម ម៉េងឃី
មេធាវី ឡោ ជុនធី
មេធាវី ម៉ុច សុវណ្ណារី
មេធាវី ស៊ិន សុវ៉ន
លោក គង់ ពិសី
លោក យ៉ុង ផានិត
មេធាវី សំ សុគង់
មេធាវី វ៉េន ពៅ
មេធាវី ទី ស្រ៊ុនណា
មេធាវី Emmanuel ALTIT
មេធាវី Pascal AUBOIN
មេធាវី Olivier BAHOUGNE
មេធាវី Patrick BAUDOIN
មេធាវី Evelyne BOILEAU-BRANDOMIR
មេធាវី Philippe CANONNE
មេធាវី Annie DELAHAIE
មេធាវី Laure DESFORGES
មេធាវី Ferdinand DJAMMEN NZEPA
មេធាវី Nicole DUMAS
មេធាវី Isabelle DURAND
មេធាវី Françoise GAUTRY
មេធាវី Marie GUIRAUD
មេធាវី Emmanuel JACOMY
មេធាវី Martine JACQUIN
មេធាវី Daniel LOSQ

<u>ចម្លងជូន</u>៖

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក Andrew CAYLEY

**ជនជាប់ចោទ៖**

ខៀវ សំផន
អៀង សារី
អៀង ធីរិទ្ធ
នួន ជា

**សហមេធាវីការពារក្តី៖**

មេធាវី សុន អរុណ
មេធាវី Michiel PESTMAN
មេធាវី Victor KOPPE
មេធាវី អាង ឧត្តម
មេធាវី Michael G. KARNAVAS
មេធាវី ផាត់ ពៅស៊ាង
មេធាវី Diana Ellis
មេធាវី ស សូវ៉ាន
មេធាវី Jacques VERGÈS

មេធាវី Christine MARTINEAU

មេធាវី Madhev MOHAN

មេធាវី Barnabé NEKUIE

មេធាវី Lyma Thuy NGUYEN

មេធាវី Elisabeth RABESANDRATANA

មេធាវី Julien RIVET

មេធាវី Fabienne TRUSSES NAPROUS

មេធាវី Nushin SARKARATI

មេធាវី Philippine SUTZ

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី Silke STUDZINSKY

## I. សេចក្តីផ្តើម

១. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមរំឭកបទប្បញ្ញត្តិនៃវិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង៖
*"គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ (...)"*។

២. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថា ទម្រង់ទាំងបីនៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមមានលក្ខណៈសមស្របទៅនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។

៣. ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើ ដែលមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃផែនការឧក្រិដ្ឋរួម ប៉ុន្តែជាផលវិបាកជាធម្មតា និងអាចទស្សន៍ទាយបាននៃផែនការនោះ។

## II. ការរំឭកអង្គហេតុ និងនីតិវិធី

៤. កាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ចំពោះឧក្រិដ្ឋកម្មស្ថិតក្រោមច្បាប់អន្តរជាតិ ទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួមត្រូវអនុវត្តនៅចំពោះមុខ អ.វ.ត.ក[1]។

៥. កាលពីថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ[2]។ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ចំពោះទម្រង់ពីរដំបូងនៃសហឧក្រិដ្ឋកម្មរួម។

---

[1] ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក-កសចស ឯកសារ D97/13 ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩។

[2] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ៣៨) ឯកសារ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៧៧ ("សាលដីការបស់អង្គបុរេជំនុំជម្រះលើការអនុវត្តសហឧក្រិដ្ឋកម្មរួម")។

៦. ចំពោះទម្រង់ទីបី អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ទម្រង់ទីបីមិនអាចអនុវត្តជាទម្រង់នៃការទទួលខុសត្រូវ នៅចំពោះមុខ អ.វ.ត.ក បានទេ[3]។

៧. គោលជំហរនេះត្រូវបានបញ្ជាក់សាឡើងវិញ ដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយ។

៨. តាមរយៈសំណើ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ (ឯកសារ E100)[4] សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ប្រកាសទទួលស្គាល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដោយហេតុថាជនជាប់ចោទបានចូលរួមទៅក្នុងទម្រង់ទី ៣ នៃសហឧក្រិដ្ឋកម្មរួម។

## III. ការពិភាក្សា

៩. ជាបឋម សហព្រះរាជអាជ្ញាបញ្ជាក់អំពីមូលហេតុដែលសំណើរបស់ខ្លួនអាចទទួលយកបាន យោងតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង។ សំណើប្រភេទនេះត្រូវបានទទួលយករួចមកហើយ នៅក្នុងសំណុំរឿង០០១៖ សហព្រះរាជអាជ្ញាលើកឡើងថាអង្គជំនុំជម្រះសាលាដំបូងអាចកែប្រែការកំណត់បទចោទ ដែលបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប៉ុន្តែមិនអាចផ្លាស់ប្តូរ ឬបន្ថែមធាតុផ្សំថ្មីនៃបទចោទបានឡើយ។ នៅពេលមានការផ្លាស់ប្តូរការកំណត់បទចោទ អង្គជំនុំជម្រះត្រូវតែធានាផងដែរថា មិនមានការរំលោភសិទ្ធិរបស់ជនជាប់ចោទ ហើយទម្រង់នៃការទទួលខុសត្រូវថ្មីនោះអាចយកមកអនុវត្តបាននៅអ.វ.ត.ក[5]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមគាំទ្រចំពោះការទាញហេតុផលបឋមនេះ។

---

[3] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ៣៨) ឯកសារ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៨៨ ("សាលដីការបស់អង្គបុរេជំនុំជម្រះលើការអនុវត្តសហឧក្រិដ្ឋកម្មរួម")។

[4] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដោយហេតុថាជនជាប់ចោទបានចូលរួមទៅក្នុងទម្រង់ទី ៣ នៃសហឧក្រិដ្ឋកម្មរួម។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសជ ឯកសារ E100 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

[5] សាលក្រមក្នុងសំណុំរឿងឌុច កថាខណ្ឌ ៤៩៦ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០។

១០. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមគាំទ្រទាំងស្រុង ចំពោះការទាញហេតុផលសំខាន់របស់សហព្រះរាជអាជ្ញាដែលព្យាយាមបង្ហាញថាលក្ខខណ្ឌតម្រូវសម្រាប់ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ត្រូវបានបំពេញក្នុងករណីនេះ។

## IV. សេចក្ដីសន្និដ្ឋាន

១១. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមគាំទ្រសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ប្រកាសទទួលស្គាល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដោយហេតុថាជនជាប់ចោទបានចូលរួមទៅក្នុងទម្រង់ទី ៣ នៃសហឧក្រិដ្ឋកម្មរួម។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |
| | ម៉ុច សុវណ្ណារី<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | គឹម ម៉េងឃី<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | Isabelle DURAND<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |